ជំពូក ៤

ស្ថានភាពបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គំរោង

Description of Existing Environment

Draft

ជំពូកទី ៤

ស្ថានភាពបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គំរោង

៤.១ សេចក្តីផ្តើម

ក្នុងជំពូកនេះគឺ ពិពណ៌នាអំពីស្ថានភាពធនធានបរិស្ថានដែលមានស្រាប់ (បរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និង បរិស្ថានសង្គម) ក្នុងតំបន់ទីតាំងគំរោងដែលប្រមូលពត៌មានបានពីស្ថាប័ន អង្គភាពពាក់ព័ន្ធ រួមទាំងការចុះអង្កេតសិក្សាស្រាវជ្រាវផ្ទាល់ពីមូលដ្ឋាន ដើម្បីបានទិន្នន័យគ្រឹះសម្រាប់ធ្វើការវិភាគ និងវាយតម្លៃលទ្ធផលប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) ដែលនឹង កើត ឬ អាចកើតឡើងពីសកម្មភាពនៃការអនុវត្តន៍គំរោង ។

ក្នុងជំពូកនេះក៏រាយការណ៍ខ្លះៗផងដែរអំពីសំណូមពរ និងប្រឹក្សាពិគ្រោះយោបល់ជាមួយសាធារណៈជន និង ស្ថាប័ន-អង្គភាពពាក់ព័ន្ធមួយចំនួននៅក្នុងតំបន់ទីតាំងគំរោង ។

៤.២ បរិស្ថានរូបសាស្ត្រ (Physical Environment)

៤.២.១ ឧតុនិយម និងប្រព័ន្ធជលសាស្ត្រ (Meteorology & Hydrology)

៤.២.១.១ របបទឹកភ្លៀង (Rainfall)

តំបន់ជាយអារ៉ែងនេះមានបរិមាណទឹកភ្លៀងធ្លាក់ខ្ពស់បង្គួរបើប្រៀបទៅតំបន់ផ្សេងទៀត ព្រោះវាស្ថិតនៅក្បែរតំបន់មាត់សមុទ្រ ខេត្តកោះកុងនៃប្រទេសកម្ពុជា និងនៅជ្រលងនៃជួរភ្នំក្រវាញ។ គ្មានទិន្នន័យទឹកភ្លៀងកត់ត្រានៅតំបន់គំរោងឡើយ មានស្ថានីយ៍កត់ត្រាទឹកភ្លៀងនៅជិតជាងគេនោះគឺ ស្ថានីយ៍ស្រុកបុទុមសាគរ ។

បរិមាណទឹកភ្លៀងធ្លាក់ គិតជាមធ្យមរយៈពេល ៩ ឆ្នាំ គិតពី ឆ្នាំ ១៩៩៩ ដល់ ២០០៧ (ដល់ខែកញ្ញា) នៅបុទុមសាគរ គឺ **២៩៥៨,៤៨ មម** (Return Period 9 years) (ប្រភពទិន្នន័យបានពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកោះកុង) ។

តារាងលេខ ១ : បរិមាណទឹកភ្លៀង គិតជា ម.ម ក្នុងរយៈពេល៩ឆ្នាំ (១៩៩៩-២០០៧)

Month	Jan	Feb	Mar	Apr	May	Jun	Jul	Aug	Sep	Oct	Nov	Dec	Yearly total
Years	I	II	III	IV	V	VI	VII	VIII	IX	X	XI	XII	
1999	52.90	49.80	321.90	251.50	370.90	485.60	809.20	502.30	214.30	441.70	102.80	33.10	**3636.00**
2000	46.20	98.30	198.90	130.70	318.20	523.30	859.30	**867.70**	199.10	481.70	16.40	51.60	**3791.40**
2001	64.60	49.70	104.00	150.40	329.80	831.10	452.40	687.50	285.30	222.60	54.90	82.90	**3315.20**
2002	0.30	6.20	32.40	59.20	237.90	360.50	304.50	748.20	269.00	119.10	69.80	30.60	**2237.70**
2003	3.70	8.50	215.90	230.40	350.40	193.70	575.40	431.70	510.40	261.20	21.30	0.00	**2802.60**
2004	21.30	0.00	8.40	10.20	323.80	578.00	509.50	597.10	281.60	42.94	0.00	0.00	**2372.84**
2005	0.00	0.00	0.00	75.50	61.30	352.80	732.10	286.30	372.90	308.70	71.10	28.30	**2289.00**
2006	0.00	35.80	15.20	202.00	430.70	366.60	716.50	814.99	375.95	218.08	46.87	0.00	**3222.69**
2007	0.00	40.00	44.00	71.28	316.00	344.12	427.62	315.37	265.10				
Mean	21.00	32.03	104.52	131.24	304.33	448.41	598.50	583.46	308.18	262.00	47.90	28.31	2958.43
Min	0.00	0.00	0.00	10.20	61.30	193.70	304.50	286.30	199.10	42.94	0.00	0.00	2237.70
Max	64.60	98.30	321.90	251.50	430.70	831.10	859.30	867.70	510.40	481.70	102.80	82.90	3791.40

Draft





Source: Department of Meteorology, Ministry of Water Resources and Meteorology

Draft

៤.២.១.២ សីតុណ្ហភាព (Temperature)

ប្រភពទិន្នន័យបានពី នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម បានបង្ហាញថា :

- មធ្យមភាគនៃសីតុណ្ហភាពអតិបរមារយៈពេល ១ ឆ្នាំ មានកំរិត ៣១,៩^{0}C
- មធ្យមភាគនៃសីតុណ្ហភាពអប្បបរមារយៈពេល ១ ឆ្នាំ មានកំរិត ២៣,៩^{0}C
- មធ្យមភាគនៃសីតុណ្ហភាពរយៈពេល ១ ឆ្នាំ មានកំរិត ២៧,៩^{0}C
- សីតុណ្ហភាពអតិបរមារយៈពេល ១១ ឆ្នាំ ខ្ពស់បំផុតមានកំរិត ៣៥,៣^{0}C នៅឆ្នាំ ១៩៩៩
- សីតុណ្ហភាពអប្បបរមារយៈពេល ១១ ឆ្នាំ ទាបបំផុតមានកំរិត ២០,៣^{0}C នៅឆ្នាំ ២០០៣

តារាងលេខ ២ : សីតុណ្ហភាពអតិបរមាប្រចាំ ខែ គិតជា°C ក្នុងរយៈពេល១១ឆ្នាំ (១៩៩៥-២០០៥)

Month	Jan	Feb.	Mar.	Apr.	May	Jun.	Jul.	Aug.	Sep.	Oct.	Nov.	Dec.	Yearly Mean
Years	I	II	III	IV	V	VI	VII	VIII	IX	X	XI	XII	
1995	31.0	30.2	32.5	34.2	33.2	33.7	32.2	30.2	31.3	30.0	32.3	31.3	31.8
1996	31.3	32.0	33.6	33.7	33.1	33.6	31.0	30.7	31.1	30.2	32.0	30.0	31.9
1997	31.2	32.0	35.0	35.0	34.0	34.5	32.3	30.6	31.6	31.5	31.1	31.3	32.5
1998	31.0	32.2	34.2	34.6	34.7	33.3	30.9	32.4	30.3	31.5	30.2	29.3	32.1
1999	31.5	32.6	34.2	35.3	33.3	33.1	31.5	32.0	31.0	30.9	30.2	30.6	32.2
2000	30.3	32.5	33.2	34.2	32.5	33.6	30.2	32.1	30.2	30.4	30.1	30.2	31.6
2001	31.0	32.6	33.1	34.0	32.5	30.6	26.5	30.5	29.8	31.9	31.9	32.3	31.4
2002	31.1	32.6	33.0	34.0	32.6	30.6	30.6	30.3	31.1	32.2	32.6	32.4	31.9
2003	31.0	32.7	33.3	34.3	32.4	32.1	31.0	32.3	32.0	31.2	32.0	31.0	32.1
2004	31.9	32.2	33.2	34.1	32.6	30.6	30.6	30.3	31.1	30.3	32.6	32.7	31.9
2005	31.1	32.7	32.8	33.4	32.6	31.4	29.4	30.5	29.8	30.7	32.3	31.2	31.5
Monthly mean	31.1	32.2	33.5	34.2	33.0	32.5	30.6	31.1	30.9	31.0	31.6	31.1	31.9
Max	31.9	32.7	35.0	35.3	34.7	34.5	32.3	32.4	32.0	32.2	32.6	32.7	35.3

តារាងលេខ ៣ : សីតុណ្ហភាពអប្បរមាប្រចាំ ខែ គិតជា°C ក្នុងរយៈពេល១១ឆ្នាំ (១៩៩៥-២០០៥)

Month	Jan	Feb.	Mar.	Apr.	May	Jun.	Jul.	Aug.	Sep.	Oct.	Nov.	Dec.	Yearly Mean
Years	I	II	III	IV	V	VI	VII	VIII	IX	X	XI	XII	
1995	21.0	23.5	23.4	24.6	25.3	24.9	24.1	24.3	24.4	24.5	23.3	23.2	23.9
1996	21.5	23.0	23.1	25.0	25.5	25.0	24.5	24.0	24.5	24.0	23.5	22.6	23.9
1997	21.6	22.6	24.5	25.2	24.7	24.3	23.9	23.9	24.3	24.6	24.0	22.5	23.8
1998	21.5	23.0	24.0	24.3	24.2	24.5	23.5	23.5	25.0	23.6	24.0	22.6	23.6
1999	20.6	22.9	23.5	24.3	24.3	24.1	24.0	23.2	23.6	23.5	23.5	21.9	23.3
2000	21.5	23.0	23.7	23.6	24.6	25.2	23.5	23.6	23.0	24.3	23.5	21.5	23.4
2001	22.6	23.2	24.4	24.4	25.1	25.0	24.4	24.3	24.6	24.6	24.3	23.4	24.2
2002	21.6	23.7	23.9	24.3	25.0	25.0	24.5	34.8	24.5	24.6	24.4	23.4	25.0
2003	20.3	21.8	24.0	24.9	25.0	22.3	23.8	23.5	22.0	23.9	23.6	22.7	23.2
2004	22.9	23.3	24.4	24.4	25.1	24.8	24.5	24.3	24.6	24.1	23.4	22.0	24.0
2005	21.6	23.8	23.9	24.6	25.3	25.1	24.6	34.8	24.4	24.8	24.4	23.4	25.1
Monthly mean	21.5	23.1	23.9	24.5	24.9	24.6	24.1	25.8	24.1	24.2	23.8	22.7	23.9
Min	20.3	21.8	23.1	23.6	24.2	22.3	23.5	23.2	22.0	23.5	23.3	21.5	20.3

ប្រភពទិន្នន័យបានពីក្រសួងធនធានទឹក និងឧតុនិយម. នាយកដ្ឋាន ឧតុនិយម ។

៤.២.១.៣ ល្បឿន និងទិសដៅខ្យល់ (Wind Speed and Wind Direction)

របបខ្យល់នៅខេត្តកោះកុង គ្មានការសិក្សាដោយស្ថាប័នរដ្ឋាភិបាលណាមួយទេ ។ ក្រុមការងារសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានទៅទំនាក់ទំនងលោក **ឆ្លុង សារ៉ាវុធ** ប្រធាននាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម បានបញ្ជាក់ថា ទិសដៅល្បឿនខ្យល់ក្នុងតំបន់គំរោងគ្មាន ឬ នៅខេត្តកោះកុងគ្មានទិន្នន័យទេ ក៏ប៉ុន្តែនៅឆ្នាំ ២០០៦ SAWAC បានធ្វើការទំនាក់ទំនង លោកស្រី **សេង ឥណ្ណារ៉ែត** អតីតប្រធាននាយកដ្ឋានឧតុនិយម ហើយលោកស្រីបានមានប្រសាសន៍ថា ចំពោះពន្លឺថ្ងៃនៅខេត្តជុំវិញ នាយកដ្ឋានមិនបានសិក្សាទេ ប៉ុន្តែមានទិន្នន័យចំពោះល្បឿនខ្យល់នៅខេត្តពោធិ៍សាត់ និងក្រុងព្រះសីហនុ ហើយលោកស្រីអាចយកមកធ្វើការវិភាគសម្រាប់ទិន្នន័យខ្យល់ក្នុងការប្រើប្រាស់ទិន្នន័យនេះនៅខេត្តកោះកុងបានបើចាំបាច់ (ល្បឿន និងទិសដៅខ្យល់ មើលក្នុងតារាងលេខ ៤ ខាងក្រោម) ។

តារាងលេខ ៤ : ល្បឿន និងទិសដៅខ្យល់ជាមធ្យមប្រចាំខែ ក្នុងរយៈពេល១១ឆ្នាំ (១៩៩៥-២០០៥)

Months	Jan		Feb		Mar		Apr		May		Jun		Jul		Aug		Sep		Oct		Nov		Dec	
Years	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx
1995	N	7.0	NW	7.0	S	8.0	S	7.0	NW	9.0	NW	10.0	W	9.0	NW	9.0	W	10.0	NW	6.0	W	7.0	N	6.0
1996	N	9.0	S	2.9	E	3.1	S	5.0	NW	8.0	W	8.0	W	10.0	NW	8.0	W	8.0	S	6.0	E	4.0	N	6.0
1997	N	5.0	S	3.1	N	3.5	SE	8.0	SE	8.0	W	8.0	W	8.0	W	7.0	W	8.0	NW	8.0	NW	8.0	N	8.0
1998	N	8.0	NW	2.4	S	2.3	S	8.0	S	5.0	W	8.0	NW	10.0	NW	8.0	W	7.0	S	9.0	N	8.0	NW	6.0
1999	NE	8.0	SE	2.4	SE	2.4	S	6.0	NW	8.0	W	10.0	W	12.0	W	7.0	W	8.0	NW	9.0	NW	8.0	N	6.0
2000	N	10.0	S	2.6	S	3.1	NW	4.0	NW	3.3	NW	6.0	NW	4.9	W	5.0	NW	12.0	NW	3.9	N	6.0	N	7.0
2001	N	8.0	SE	1.9	S	5.0	SE	5.0	NW	3.8	W	4.9	NW	5.0	W	5.0	W	2.6	NW	2.6	N	8.0	N	5.0
2002	N	8.0	N	2.4	SE	6.0	S	3.0	SW	6.0	NW	3.1	W	8.0	NW	4.7	NW	3.2	W	5.0	W	9.0	N	4.0
2003	NE	8.0	S	2.6	SE	5.0	S	3.0	SW	6.0	NW	5.0	W	8.0	NW	4.0	W	10.0	W	6.0	W	5.0	NW	5.0
2004	N	3.5	S	1.9	S	2.3	SE	2.0	SW	5.0	W	2.5	NW	2.3	NW	2.5	NW	2.3	NW	5.0	W	2.1	N	8.0
2005	S	5.0	SE	4.0	SE	7.0	NW	6.0	NW	5.0	W	6.3	W	7.3	NW	7.5	W	6.8	NW	9.2	NW	7.0	NW	6.0
Dir	354		185		97		175		230		253		265		270		230		287		345		358	

ប្រភពទិន្នន័យបានពីក្រសួងធនធានទឹក និងឧតុនិយម, នាយកដ្ឋាន ឧតុនិយម ។

៤.២.១.៤ សំណើមបរិយាកាស (Humidity) និង កំដៅថ្ងៃ (Sunlight)

យោងតាមប្រភពពត៌មានរបស់នាយកដ្ឋានឧតុនិយមនៃក្រសួងធនធានទឹក និងឧតុនិយម គ្មានការសិក្សា និងគ្មានទិន្នន័យដែលបានធ្វើក្នុងតំបន់ ឬ ក្នុងខេត្តកោះកុង នោះទេ ឬខេត្តជុំវិញនោះទេ ។

Draft

៤.២.១.៥ គុណភាពខ្យល់

តំបន់គំរោងនេះស្ថិតនៅក្នុងតំបន់ជនបទដាច់ស្រយាលនៃស្រុកថ្មបាំង ហើយមានចំងាយប្រមាណ ៨៨គ.ម ពីក្រុងកោះកុង ដែលជាតំបន់មានព្រៃឈើ និងដីកសិកម្ម នៅក្នុងតំបន់គំរោងគ្មានតំបន់ទីប្រជុំជន ឬតំបន់ឧស្សាហកម្ម ឬពាណិជ្ជកម្មទេ ចំពោះផ្លូវថ្នល់មានផ្លូវលំជនបទគ្មានស្ពានរឹងមាំទេមានតែស្ពានបណ្តោះអាសន្នហេតុដូច្នេះហើយនៅក្នុងតំបន់គំរោងនោះគឺគុណភាពខ្យល់មានលក្ខណៈនៅជាធម្មជាតិ គ្មានការបំពុលខ្យល់ទេ ហើយក៏គ្មានទិន្នន័យណាដែលបញ្ជាក់ពីការបំពុលខ្យល់នៅតំបន់នោះដែរ ។ ចំពោះការធ្វើតេស្តរកគុណភាពខ្យល់នៅក្នុងតំបន់គំរោងនោះ មិនចាំបាច់ធ្វើតេស្តទេ ព្រោះតំបន់នោះជាតំបនជនបទ ហើយមានព្រៃឈើដូចបានចែង និងរៀបរាប់ខាងលើ ។ ប៉ុន្តែអាចមានបញ្ហាការបំពុលខ្យល់នៅតាមផ្លូវលំជនបទពីស្រុកថ្មបាំង ទៅឃុំថ្ម ដូនពៅ ឃុំជំនាប់ និងឃុំប្រឡាយនៅរដូវប្រាំង គឺដោយសារការហុយដីនៃផ្លូវនេះ ព្រោះផ្លូវនេះមិនមានក្រាលកៅស៊ូទេ ។

៤.២.១.៦ សំលេង និងរំញ័រ

ដូចបានបង្ហាញនៅក្នុងចំណុចគុណភាពខ្យល់រួចមកហើយ ពោលគឺតំបន់គំរោង មិនស្ថិតនៅក្នុងតំបន់ទីប្រជុំជន ឬតំបន់ពាណិជ្ជកម្ម ឬតំបន់ឧស្សាហកម្មទេ ដូចនេះគ្មានការបំពុលណាមួយដោយសារសំលេង និងរំញ័រគួរឱ្យកត់សំគាល់ទេ ក្រៅពីសំលេងម៉ូតូ រថយន្តតូច រទេះគោ គោយន្តតិចតួចនៅតាមផ្លូវចេញចូលទៅឃុំទាំង ៣ នៃស្រុកថ្មបាំង ព្រមទាំងសំលេងសត្វព្រៃស្រែក ដូចជាសត្វទោច បក្សីចកវ៉ែក ពវ៉ាង កេងកងជាដើម ។ល។

៤.២.១.៧ ប្រព័ន្ធអូរទន្លេ និងប្រព័ន្ធដោះទឹកក្នុងតំបន់គំរោង

(River System and Drainage Pattern in the Project Area)

ការសិក្សាតាមរយៈផែនទី JICA ឆ្នាំ ២០០៣ និងការចុះអង្កេតផ្ទាល់ដល់ទីតាំងគំរោង លើផ្ទៃដីប្រមាណជាង ១២.000 ហិកតា មានប្រព័ន្ធដោះទឹកជាលក្ខណៈធម្មជាតិដូចតទៅ :

- អាងរងទឹកភ្លៀងសរុបរបស់ស្ទឹងជាយអារ៉ែង គិតត្រឹមទំនប់វារីអគ្គិសនីនេះ (Site A) គឺប្រមាណ ៩៤៥ Km^2 (ប្រភពទិន្នន័យ China Southern Power Grid Co., Ltd.) ។
- ទឹកភ្លៀងត្រូវបានដោះតាមប្រឡាយធម្មជាតិជាច្រើនរួចហូរចុះទៅអូរធម្មជាតិសំខាន់ៗ ដូចជា ស្ទឹងទាស ស្ទឹងតូច អូរថ្មបាំង អូរក្តី អូរត្រពែក អូរសង្កែ អូរគ្រុង អូរឫស្សី អូរសំរោង អូរប្រឡាយ ស្ទឹងសាច់ស អូរតាភោក ស្ទឹងទឹកថ្នាស ស្ទឹងដា ស្ទឹងឫស្សីស្រុកជាដើម ។ ស្ទឹងអូរទាំងនោះមានបែកជាប្រឡាយតូច ដែលជាសាខារបស់វាជាច្រើនទៀត អូរទាំងនោះហូរចូលក្នុងស្ទឹងជាយអារ៉ែង ហើយស្ទឹងជាយអារ៉ែងនេះហូរចូលទៅព្រែកត្រពាំងរូង(មើលផែនទីលេខ១) ។
- យោងតាមទិន្នន័យសិក្សាដោយក្រុមហ៊ុន China Southern Power Grid Co., Ltd. ទៅលើផ្ទៃកជលសាស្ត្ររបស់ស្ទឹងជាយអារ៉ែងត្រង់ទំនប់ Site A បានបង្ហាញដូចតទៅ (ទិន្នន័យនេះយកទៅគណនាធ្វើហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី) :
  - ធារទឹកជាមធ្យមប្រចាំឆ្នាំ 56.9 m^3/s
  - ការគណនាធារទឹកជំនន់ (P=1%) 3730 m^3/s
    Design Flood Discharge (P=1%)
  - ការគណនាផ្ទៃរងផ្ទាត់ធារទឹកជំនន់ (P=0.02%) 6650 m^3/s
    Check Flood Discharge (P=0.02%)

Draft

- សីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំ 27.8 °C
- សីតុណ្ហភាពអតិបរមាប្រចាំឆ្នាំ 35.3 °C
- សីតុណ្ហភាពអប្បបរមាប្រចាំឆ្នាំ 20.3 °C
- សំណើមជាមធ្យមប្រចាំឆ្នាំ 78 %
- ល្បឿនខ្យល់អតិបរមា 20 m/s
- កំពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំ 2750 mm
- រំហួតជាមធ្យមប្រចាំឆ្នាំ 1440 mm
- កំហាប់ល្បាប់ជាមធ្យមប្រចាំឆ្នាំ 0.164 kg/m^3
- ការនាំល្បាប់ជាមធ្យមប្រចាំឆ្នាំ 295,000 តោន
- កំណកល្បាប់នៅបាតស្ទឹងជាមធ្យមប្រចាំឆ្នាំ 58,900 t
- មូលដ្ឋានស្នាមប្រេះកើតឡើងពីការរញ្ជួយដី Basic Earthquake Fissure <6°

- ***<u>លក្ខណៈជលសាស្ត្ររបស់ស្ទឹងជាយអារ៉ែង</u>***

យោងតាមទិន្នន័យខាងលើបានបង្ហាញឱ្យឃើញថា ការគិតតាមប្រូបាប៊ីលីតេធារទឹកជំនន់ (P=0.02%) ដែលអាចកើតមាន ៦៦៥០ ម^3/វិនាទី នៅរដូវវស្សា ហើយយោងតាមតារាងខាងក្រោម ធារទឹកដែលតិចជាងគេគឺ នៅ ខែមិនា ឆ្នាំ ១៩៨៧ មាន ៣.៦២ ម^3/វិនាទី ។ ស្ទឹងអារ៉ែងមានឈ្មោះពីរផ្សេងទៀត គឺផ្នែកខាងលើហៅថា ស្ទឹងជាយអារ៉ែង និងផ្នែកខាងក្រោមហៅថា ព្រែកត្រពាំងរូង ហើយព្រែកនេះនៅរដូវប្រាំងទឹកសមុទ្រ (ទឹកភ្លៀវ) ហូរចូលមកដល់ក្បាលឆាយ ។

<u>តារាងលេខ១៥</u> : បរិមាណធារទឹកជាមធ្យមក្នុងខែមិនា និង មេសា ក្នុងរយៈពេល៤២ឆ្នាំ (១៩៥៧-២០០១) គិតជា ម^3/វិនាទី

Year Month	March	April	Year Month	March	April
1957	4.22	4.22	1981	4.34	33
1958	4.9	26.2	1982	51.4	52.3
1959	36.0	22.3	1983	4.98	9.48
1960	26.3	33.1	1984	13.0	52.2
1961	19.8	47.2	1985	12.4	52.1
1962	7.21	40.9	1986	5.08	20
1963	26.7	7.13	1987	3.62	18.4
1964	6.02	40.2	1988	17.1	36.5
1965	16.7	35.4	1989	29.6	29.3
1966	15.9	39.9	1990	9.23	14.3
1967	11.8	35.4	1991	22.4	45.4
1968	4.87	34.5	1992	3.95	6.49
1969	14.1	12.7	1993	17.0	21.7
1970	5.95	48.2	1994	39.1	20
1971	13.7	9.73	1995	6.89	29.6
1972	25.5	61.9	1996	5.83	53
1973	17.8	29.2	1997	6.63	40.3
1974	10.9	24.8	1998	4.64	5.13
1975	14.2	36.6	1999	34.6	98
1979	11.4	46.2	2000	28.8	58.8
1980	21.2	22.5	2001	33.9	34.0
Mean				15.94	33.05
Min				3.62	4.22

ប្រភពទិន្នន័យបានពី China Southern Power Grid Co., Ltd.

Draft


Discharge of Chay Areng River at Dam Site A in March
(42 Years of Records 1957-2001)
Discharge (m³/s)
Year
51.4
3.62


Discharge of Chay Areng River at Dam Site A in April
(42 Years of Records 1957-2001)
Discharge (m3/s)
Year
98
4.22

Draft

តារាងលេខ ៦ : បរិមាណការហូរទឹកជាមធ្យមដែលបានវាស់ ខែមិថុនា ដល់ ខែតុលា ឆ្នាំ ២០០៧)

Date	Width of river (m)	Average velocity of flow (m/s)	flow (m^3/s)
12/6/2007	69.0	**0.701**	**28.12**
23/06/2007	70.5	0.766	40.86
13/07/2007	81.0	1.227	114.93
24/07/2007	72.6	0.809	47.96
2007/8/13	81.3	1.259	143.02
2007/8/26	80.2	1.221	113.83
2007/9/14	81.2	1.221	133.35
2007/9/20	82.0	**1.392**	**174.83**
2007/10/20	67.0	0.818	87.15
Max		**1.39**	**174.83**
Min		**0.7**	**28.12**

ប្រភពទិន្នន័យបានពី China Southern Power Grid Co., Ltd.

៤.២.១.៧ ការវិភាគគុណភាពទឹក (Water Quality Analysis)

ការវិភាគគុណភាពទឹកនៅក្នុងតំបន់គំរោង ត្រូវបានក្រុមសិក្សារបស់ SAWAC ជ្រើសរើស៤ចំណុច គឺនៅខាងលើទំនប់ Dam Site A នៅក្រោមទំនប់ Dam Site A ចន្លោះអគារថាមពល ខ្សែទឹកខាងក្រោមអគារថាមពល និង នៅអណ្តូងខួងរបស់ក្រុមហ៊ុន។

ទីតាំងយកសំណាកទឹកមានបង្ហាញដូចខាងក្រោមនេះ-:

- ចំណុចទី ១ គឺនៅក្នុងអាង ខាងលើទំនប់ Dam Site A ដែលមាន កូអ័រដោនេ X= 340884 និង Y= 1286021 នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។
- ចំណុចទី ២ នៅចន្លោះខាងក្រោម Dam Site A និងខាងលើអគារថាមពល ដែលមានកូអ័រដោនេ X= 340294 និង Y= 1285654 នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។
- ចំណុចទី ៣ នៅខាងក្រោមអគារថាមពល ដែលមានកូអ័រដោនេ X= 328624 និង Y= 1274043 នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៧ ។ (សូមមើលផែនទី ទី២ និង ៣)
- ចំណុចទី ៤ នៅអណ្តូងខួងរបស់ក្រុមហ៊ុន ដែលមានកូអ័រដោនេ X= 340423 និង Y= 1285778 នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៧ ។

សំណាកទឹកនៃខ្សែទឹកខាងលើ និង ខាងក្រោមទំនប់ត្រូវបានយក និងធ្វើការវិភាគក្នុងអំឡុងពេលសិក្សាវាយតំលៃបរិស្ថាន ខែវិច្ឆិកា និង ខែធ្នូ ឆ្នាំ ២០០៧ នេះ ហើយលទ្ធផលគុណភាពទឹកមានបង្ហាញជូនក្នុងតារាងលេខ ៧ និង ៨ ។ ចំពោះលទ្ធផល ពិសោធន៍គុណភាព ទឹកច្បាប់ដើមមានភ្ជាប់នៅឧបសម្ព័ន្ធ ២ ។

Draft

តារាងលេខ ៧: លទ្ធផលនៃការពិសោធន៍គុណភាពទឹកប្រៀបធៀបលទ្ធផលទៅនឹងស្តង់ដារបស់ក្រសួងបរិស្ថាន

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈ សម្រាប់រក្សាជីវសាស្ត្រចំរុះ MoE	លេខសំណាក			
				1 ខាងលើទំនប់	2 ខាងក្រោមទំនប់	3 ខាងក្រោមអគារថាមពល	4 អណ្តូងខួង
1	Manganese (Mn)	mg/l	-	0.1	0.05	0.1	0.02
2	Iron (Fe)	mg/l	-	0.50	0.50	0.37	0.05
3	Dissolved Oxygen (DO)	mg/l	2 - 7.5	6.83	6.89	7.61	-
4	BOD_5	mg/l	1 – 10	5.10	4.30	3.70	-
5	COD	mg/l	< 1 – 8	20.30	18.17	18.21	-
6	Total Coliform	MPN/100ml	< 1000	1300	1300	1500	220
7	pH	No Unit	6.5 – 8.5	6.8	6.5	7.6	6.75
8	Temperature (t^oc)	^oC	-	25.6	25.7	26	25.1
9	Conductivity	µS/Cm	-	14.8	14.4	17.5	560
10	TDS	mg/l	-	7.4	7.2	8.7	280
11	Turbidity	NTU	-	5	9	4	4.7
12	Total Suspended Solid (TSS)	mg/l	1-15	35.71	37.23	33.10	-
13	Total Nitrogen (TN)	mg/l	0.1 - 0.6	0.07	0.09	0.09	-
14	Total Phosphorus (TP)	mg/l	0.005 - 0.05	0.05	0.06	0.05	-

MoE : ក្រសួងបរិស្ថាន (ស្តង់ដាគុណភាពទឹកក្នុងប្រភពទឹក សាធារណៈ សម្រាប់រក្សាជីវសាស្ត្រចំរុះ ចំពោះ ទន្លេ និង អាងស្តុកទឹក)

តារាងលេខ៨ : លទ្ធផលនៃការពិសោធន៍គុណភាពទឹកប្រៀបធៀបលទ្ធផលទៅនឹងស្តង់ដារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដាគុណ ភាពទឹកផឹក MIME	លេខសំណាក			
				1	2	3	4
1	Manganese (Mn)	mg/l	0.1	0.1	0.05	0.1	0.02
2	Iron (Fe)	mg/l	0.3	0.50	0.50	0.37	0.05
3	Dissolved Oxygen (DO)	mg/l	-	6.83	6.89	7.61	-
4	BOD_5	mg/l	-	5.10	4.30	3.70	-
5	COD	mg/l	-	20.30	18.17	18.21	-
6	Total Coliform	MPN/100ml	0	1300	1300	1500	220
7	pH	No Unit	6.5 – 8.5	6.8	6.5	7.6	6.75
8	Temperature (t^oc)	^oC	-	25.6	25.7	26	25.1
9	Conductivity	µS/Cm	< 1500	14.8	14.4	17.5	560
10	TDS	mg/l	< 800	7.4	7.2	8.7	280
11	Turbidity	NTU	< 5	5	9	4	4.7
12	Suspended Solid (SS)	mg/l	-	35.71	37.23	33.10	-
13	Total Nitrogen (TN)	mg/l	-	0.07	0.09	0.09	-
14	Total Phosphorus (TP)	mg/l	-	0.05	0.06	0.05	-

MIME : ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Draft

យោងតាមតួលេខនៃការវិភាគទឹកខាងលើបានបង្ហាញថា មានពីរប៉ារ៉ាម៉ែត្រគឺ Total Coliform និង Fe ដែលលើសពីតំលៃស្តង់ដាសម្រាប់ទឹកផឹករបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) (មើលតារាងលេខ ៨)។ មាន ៤ ប៉ារ៉ាម៉ែត្រដែលលើសពីតំលៃស្តង់ដាសម្រាប់គុណភាពទឹកក្នុងប្រភពទឹកសាធារណៈសម្រាប់រក្សាជីវសាស្ត្រចំរុះរបស់ក្រសួងបរិស្ថាន ។ នៅពេលយកសំណាកមកពិសោធន៍ គឺទឹកស្ទឹងស្រកទៅវិញហើយព្រោះជារដូវប្រាំង (ថ្ងៃទី ២១ វិច្ឆិកា និង ១៦ ធ្នូ ឆ្នាំ ២០០៧)។

- <u>Total Coliform</u> គឺទឹកដែលក្រខ្វក់អាចមានចំនួនច្រើននូវពពួកមេរោគផ្សេងៗទៀត ។ ពពួកមេរោគទាំងនោះមាន ដូចជាបាក់តេរី, ពងព្រួន, វិរុស ឬ **protozoa** យើងព្យាយាមរកប្រភេទមេរោគទាំនោះ ដែលអាចមាននៅក្នុងទឹកបច្ចុប្បន្ន ហើយដែលចំណាយពេល និងថវិកាដ៏ច្រើន ។ វាអាចធ្វើការវិភាគនៃអតិសុខុមជីវសាស្ត្រទឹកដោយអស់តំលៃថោករហ័សហើយ និងងាយស្រួលទៀតផង ។ នេះគឺមូលហេតុថា ហេតុអ្វីបានជាធម្មតា គេធ្វើការវិភាគរកឱ្យឃើញពិតប្រាកដនូវ "សន្ទស្សន៍បាក់តេរី" (indicator bacteria) ។ សន្ទស្សន៍បាក់តេរីនេះជាបាក់តេរីដែលគេជានិច្ចកាលរកឃើញនៅក្នុងលាមកមនុស្សទោះបីមនុស្សនោះជា ឬក៏ឈឺក៏ដោយ ។ គេអាចនិយាយថា បើគេរកឃើញបាក់តេរីនេះមាននៅក្នុងទឹកគេសន្នត់ថាទឹកនេះបំពុលដោយលាមកមនុស្ស ។ បាក់តេរីកូលីហ្វូមពីលាមកនេះ កើតមានឡើងជាធម្មជាតិនៅពោះវៀនមនុស្ស ដោយវាធ្វើការជំនួយដល់ការរំលាយអាហារ ។ ពួកគេក៏ឃើញមានផងដែរនៅក្នុងលាមកពពួកសត្ត ដែលមានឈាមក្តៅ ។ Faecal Coliform <u>*បាក់តេរីដោយខ្លួនឯងមិនធ្វើឱ្យមានជំងឺទេ*</u> ។ លាមកនៃមនុស្សខ្លះអាចមានផងដែរ នូវមេរោគផ្សេងៗ នៅពេលគេមានជំងឺ ។ <u>*ដូច្នេះបើគេដឹងពិតប្រាកដនៅក្នុងទឹកនោះបំពុលដោយលាមកមនុស្សនោះទឹកនេះក៏បំពុលផងដែរ ដោយសារមេរោគផ្សេងៗដែលមាននៅក្នុងលាមកមនុស្ស*</u> ។

ឥទ្ធិពលដល់សុខភាព : ដោយសារតែរកឃើញមាន Faecal Coliform ដែលបង្ហាញឱ្យដឹងនូវមេរោគជាច្រើនប្រភេទ ដូចជាវីរុស, បាក់តេរី ដង្កូវប៉ារ៉ាស៊ីត... ដែលរស់នៅ ក្នុងទឹកជានិច្ចកាលនាំមកនូវគ្រោះថ្នាក់នៃមេរោគទាំងនោះ (បង្កជាជំងឺ) ដែលជាភ្នាក់ងារចម្លងតាមប្រភពទឹកពីសត្ត្វមកមនុស្សពីមនុស្សទៅសត្ត្ব ហើយដែលអាចមានសភាពធ្ងន់ទាមទារឱ្យមានសកម្មភាពទប់ស្កាត់ជាបន្ទាន់ ។ ស្តង់ដាគុណភាពទឹកសម្រាប់ផឹករបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានបញ្ជាក់ថា Total Coliform ត្រូវមានកំរិតសូន្យ ។

- <u>Fe</u> ដែលមាននៅក្នុងស្ទឹងជាយអារ៉ែងនេះលើសពីស្តង់ដាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលអាចបណ្តាល មកពីការសំយោគវារីជាតិ រុក្ខជាតិទឹក ជ្រុំវិញ និងរ៉ែនៅក្នុងតំបន់ដែលទឹកបានហូរនាំយកមក ។

  Fe នៅក្នុងទឹកសំដែងឡើងជា mg/l (Fe) ម្យ៉ាងវិញទៀតដែកគ្មានផ្តល់ឥទ្ធិពលអាក្រក់ដល់សុខភាពទេ តែមានបញ្ហាខ្លះដែលកើតឡើងដោយសារក្នុងទឹកមានកំហាប់របស់វាដែរ ។ បញ្ហានេះគឺរសជាតិទឹក ធ្វើឱ្យសំលៀកបំពាក់ប្រឡាក់ពណ៌ក្រហម ពេលដែលយើងបោសសំអាតវា និងធ្វើឱ្យស្ទះនៃប្រព័ន្ធទុយោចែកចាយទឹក ។ ដែកវាមិនរលាយក្នុងទឹកទេតែវាប៉ះជាមួយ និងអុកស៊ីសែន (O_2) ក្នុងខ្យល់វាក្លាយជាសំណក (បង្កជាកំណកវ៉ែងតូចៗ) នៅក្នុងទឹកដោយយោងតាតសមីការដូចតទៅ :

  $Fe^{2+} O_2 \rightarrow FeO \downarrow$

  (អ៊ីយ៉ុងដែក II) + (អុកស៊ីសែននៃខ្យល់) -> (កំណត់ដែកអុកស៊ីតដែលធ្លាក់ទៅក្រោម)

  $Fe^{3+} O_2 \rightarrow Fe2O_3 \downarrow$

(Ironion III) + (អុកស៊ីសែននៃខ្យល់) -> (កំណប្រ្ចេះដែកធ្លាក់ទៅក្រោម)

ផលវិបាក :

រស់ជាតិ : អ៊ីយ៉ុងដែក Fe^{2+} និង Fe^{3+} ដែលរលាយនៅក្នុងទឹកធ្វើឱ្យទឹកមានរសជាតិមិនល្អ នាំមនុស្សមិនចូលចិត្តផឹកទឹកនោះ ។

ប្រឡាក់សំលៀកបំពាក់ : ពេលដែលសំលៀកបំពាក់ ត្រូវបោកសំអាត និងទឹកដែលមានអ៊ីយ៉ង់ដែករលាយក្នុងនោះធ្វើឱ្យខោអាវ ឡើងពណ៌ត្នោតស្រាល ឬក៏ពណ៌ច្រេះដែក ។

ការធ្វើឱ្យស្ទះ : សំណាញ់ចឹតសំរាប់ស្នប់ដៃរបស់អណ្តូងទឹកអាចស្ទះដោយសារតែច្រេះ និងបាក់តេរីដែកដែល មាននៅក្នុងទឹក ហើយ កំណច្រេះដែកនេះធ្វើឱ្យស្ទះបណ្តាញទុយោប្រព័ន្ធចែកចាយទឹកទៀតផង ។

បើ Fe មានលើសពី ៥ mg/l ធ្វើឱ្យទឹកមានពណ៌ និងមានភាពល្អក់ ។

ស្ត្រង់ដា : ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល បានណែនាំសំរាប់ទឹកផឹក កំហាប់ដែកមានច្រើនបំផុតត្រឹម ០,៣ ម.ក្រ/លីត្រ ពីព្រោះគេពិនិត្យពិច្ចយលើសោភ័ណ្ឌភាពទឹក ។ មានប្រទេសខ្លះដូចជា រុស្សីអាចឱ្យកំហាប់នេះខ្ពស់ពី ០,៣ - ០,៥ ម.ក្រ/លីត្រ ។

- **<u>ការតំរូវការអុកស៊ីសែនសំរាប់គីមី (COD)</u>** គឺបញ្ជាក់អំពីការប្រើប្រាស់អុកស៊ីសែនរបស់សារធាតុគីមីដែលរលាយក្នុងទឹកក្នុងដែលត្រូវការធ្វើប្រតិកម្មគីមីគឺ អុកស៊ីតកម្ម ។ កំហាប់របស់វាសំដែងឡើងជា mg/l (COD) ។

  គេធ្វើតេស្ត៍រក COD សំដែងឡើងជាប៉ូតាស្យូមពែម៉ង់កាណាត ($KMnO_4$) ឬប៉ូតាស្យូមឌីក្រូមម៉ាត ($K_2Cr_2O_7$) ដែលមានតំលៃដូចគ្នា ។

  <u>សំគាល់</u>:ចំពោះទឹកដែលមាន DO ទាបហើយនោះ ក៏មានសារធាតុគីមីនៅក្នុងទឹកច្រើនដែរ ដែលសារធាតុគីមីទាំងនោះត្រូវការអុកស៊ីសែនដើម្បីធ្វើអុកស៊ីតកម្ម ដូច្នេះមូលហេតុទឹកដែលមានអុកស៊ីសែនតិចក៏ដោយសារ COD ខ្ពស់ផងដែរ ។

ផលវិបាក:

ឥទ្ធិពលដល់សុខភាព : ពុំមានតួលេខណែនាំមូលដ្ឋានសុខភាពណាមួយត្រូវបានគេលើកជាអនុសាសន៍សំរាប់ COD ក្នុងទឹកផឹកនោះទេ។ ទោះបីជាយ៉ាងនេះក៏ដោយបើទឹកមាន COD ខ្ពស់ក៏បញ្ជាក់ផងដែរអំពីគុណភាពអន់របស់ទឹក ។ ម្ល៉ើទឹកមាន COD ទាបគឺទឹកនោះមិនបំពុលដោយសារសារធាតុគីមីដែលធ្វើអុកស៊ីតកម្មនោះទេ។ ក្រសួងបរិស្ថានបានកំណត់គុណភាពទឹកទន្ទេសំរាប់រក្សាការពារជីវចំរុះសំរាប់អាងទឹកធំ១ គឺ DO ស្ថិតក្នុងកំរិត ពី 2.0 - 7.5 mg/l ។

<u>សំគាល់</u> : ពុំមានតួលេខណែនាំមូលដ្ឋានសុខភាពណាមួយត្រូវបានគេលើកជាអនុសាសន៍សំរាប់ DO ក្នុងទឹកផឹកនោះទេ ។ ទោះបីជាយ៉ាងនេះក៏ដោយ បើទឹកគ្មាន DO ឬមានតិច ក៏បញ្ជាក់ដែរអំពីគុណភាពអន់របស់ទឹក ។ បើទឹកមានអុកស៊ីសែនខ្ពស់ក្នុងការផ្គត់ផ្គង់ទឹកស្អាតអាចធ្វើឱ្យនីត្រាតប្រតិកម្មជាមួយអុកស៊ីសែនទៅជានីត្រីត ហើយស៊ុលហ្វាតឱ្យទៅជាស៊ុលហ្វីត ហើយ ដែកឱ្យទៅជាច្រែសដែកដែលកាត់បន្ថយកិនរស់ជាតិរបស់ទឹកផឹកនោះ ។ ម្យ៉ាងទៀតការបង្កើនអុកស៊ីសែននៅក្នុងទឹកដែលផ្គត់ផ្គង់អាចធ្វើឱ្យបាក់តេរីបន្ថយការបង្កើតនីត្រាត និងស៊ុលហ្វាតដែរ ។ ចំពោះត្រីបើ DO ទាបអាចធ្វើឱ្យត្រីងាប់ ។

Draft

- TP ប្រភពសំខាន់នៃផូស្វ័រនៅក្នុងទឹកមានដោយសារការស្លាប់នៃរុក្ខជាតិ ឬសត្ត ហើយវាក៏ធ្លាក់ចូលក្នុងដី និងទឹក ។ មានប្រភព ផ្សេងទៀតនៃ P មកពី ជីគីមី, ឆ្អឹងសត្ត និងមនុស្ស ។

គេរកឃើញផូស្វ័រ សំបូរជាធម្មតានៅក្នុងទំរង់ជាអង្គធាតុសមាសនានា ដូចជា ផូស្វាតអាប៉ាទីត ។ល។ ផូស្វ័រមានសណ្ឋានវិសមរូប ៣ យ៉ាងគឺ :

១- ផូស្វ័រ ស ដែលជាសារធាតុរឹងពុល មិនរលាយក្នុងទឹក ហើយឆេះដោយឯកឯងនៅក្នុងខ្យល់ ដែលមើលឃើញនៅពេលយប់ ហើយប្រជាពលរដ្ឋខ្មែរជឿថា ជាភ្លើងព្រាយ ឬខ្ចោច ។

២- ផូស្វ័រក្រហម ដែលជាម្សៅមិនពុល មិនរលាយក្នុងទឹក និងមានសកម្មភាពគីមីខ្សោយជាងផូស្វ័រស ។

៣- ផូស្វ័រជាធាតុគីមីយ៉ាងសំខាន់សំរាប់ការលូតលាស់របស់សត្ត និងរុក្ខជាតិ ហើយវាជាសារធាតុបង្កយ៉ាងសំខាន់នៃប្រូតេអ៊ីនជាលិកាប្រសាទ ឆ្អឹង និងធ្មេញ ។ នៅក្នុងឧស្សាហកម្មគេផលិតផូស្វ័រដោយដុតរ៉ែកាល់ស្យូមផូស្វាត ($Ca_3(PO_4)_2$) ។

មានអំបិលផូស្វាតផ្សេងទៀតដូចជា ម៉ូណូសូដ្យូមផូស្វាត (NaH_2PO_4) , ទ្រីសូដ្យូមផូស្វាត (Na_3PO_4) ។ល។ ផូស្វាតនេះជាសារធាតុចិញ្ចឹមយ៉ាងសំខាន់សំរាប់សត្ត និងរុក្ខជាតិ ហើយជីផូស្វាតត្រូវប្រើប្រាស់យ៉ាងទូលំទូលាយក្នុងវិស័យកសិកម្ម ។

ទឹកធម្មជាតិដែលពេលខ្លះវាមានកំហាប់ផូស្វាតខ្ពស់ ដោយសារការប្រើប្រាស់ជីគីមីហួសកំរិតលើវិស័យកសិកម្ម ហើយវាហូរចូលទៅក្នុងប្រភពទឹកដែលធ្វើឱ្យទឹកនោះមានការលូតលាស់ហួសប្រមាណនៃពពួកវារីជាតិដូចជា សារាយ ចក កំប្លោក ។ល។ នៅក្នុងទឹកគេធ្វើការវិភាគផូស្វ័រសរុប (TP) បានន័យថា គឺរកសារធាតុផូស្វ័រសរុប (ទោះវានៅក្នុងបង្គុំម៉ូលេគុលអំបិលផូស្វាតក៏ដោយ) ដែលមាននៅក្នុងទឹក ។ ពេលដែលត្រួតពិនិត្យប្រភពទឹករយៈពេលយូរ គេសង្កេតឃើញកំរិត TP មានការកើនឡើង នោះបានន័យថា ទឹកនោះចាប់ផ្តើមបំពុលដោយការប្រើជីគីមីក្នុងវិស័យកសិកម្ម ឬពីការលួយពុកផុយនៃរុក្ខជាតិ ។

ផលវិបាក:

ផូស្វ័រសរុប បើគេរកឃើញមានច្រើននៅក្នុងទឹកលើសពី 0.05 **mg/1** នោះ ទឹកនោះនឹងដុះនូវវារីជាតិជាច្រើនមិន ខានដែលធ្វើឱ្យប៉ះពាល់ដល់ត្រី និងជីវៈចំរុះនៅក្នុងទឹក ។

គោលការណ៍ណែនាំនៃកំរិតអតិបរិមាដែលបានអនុញ្ញាតិឱ្យ:

អង្គការសុខភាពពិភពលោក មិនបានធ្វើការណែនាំអំពីកំរិតផូស្វ័រ ឬ ផូស្វ័រសរុបនៅក្នុងទឹកផឹកទេ ព្រោះផូស្វ័រមិនរលាយក្នុងទឹក ។ ម្យ៉ាងទៀតមានតែអំបិលផូស្វាតប៉ុណ្ណោះដែលរលាយក្នុងទឹក ហើយគ្មានស្តង់ដាសំរាប់វាដែរ ចំពោះការផ្តត់ផ្គង់ទឹកស្អាតសំរាប់ផឹក ។

Draft

<u>សន្និដ្ឋានលើគុណភាពទឹកក្នុងតំបន់គំរោងវារីអគ្គិសនីដែលមិនទាន់ជំណើរការអនុវត្តន៍គំរោង</u> :

គុណភាពទឹកស្ទឹងជាយអារ៉ែងស្ថិតនៅផ្នែកខាងលើទំនប់ Site A ពុំមានឃើញមានបញ្ហាការបំពុលធំដុំអ្វីទេ ក្រៅពីសកម្មភាពធម្មជាតិ (ភ្លៀងខ្លាំងនាំឱ្យហូរច្រោះ ឬបាក់ដី និងការនាំយកកំណាត់ឈើ ស្លឹកឈើ ចូលទឹកស្ទឹង) ។

ផ្អែកលើការសង្កេតមើលឃើញដោយភ្នែក ការយកពត៌មានពីប្រជាពលរដ្ឋមូលដ្ឋាន និងតាមតារាងគុណភាពទឹកខាងលើ ឃើញថា គុណភាពទឹកស្ទឹងជាយអារ៉ែងផ្នែកខាងក្រោមទំនប់នេះដែលស្ថិតនៅចន្លោះទំនប់ និងអគារថាមពល មានការបំពុលតិចតួចពីសកម្មភាពមនុស្ស និងធម្មជាតិប៉ុណ្ណោះ ។

ការបំពុលពីសកម្មភាពមនុស្សរួមមាន:

- ការប្រើប្រាស់ជី និង ថ្នាំពុលកសិកម្ម លើដីដំណាំ នានាសងខាងស្ទឹងតិចតួច (សំណល់ជី និងថ្នាំពុលទាំងនោះអាចជ្រាប ឬ ហូរចូលក្នុងស្ទឹង)
- ការចុះងូតទឹក និងការបោកគក់ លាងដុសរបស់អ្នកភូមិក្នុងតំបន់
- ការចោលកាកសំណល់នានាពីអ្នកភូមិក្នុងតំបន់រួចហូរចូលប្រភពទឹកស្ទឹងនេះ

ការបំពុលពីសកម្មភាពធម្មជាតិរួមមាន :

- ការហូរច្រោះ ឬបាក់ដី និងការនាំយកកំណាត់ឈើ ស្លឹងឈើ កំទេចកំទីពុករលួយ ដោយភ្លៀងព្យុះ
- ការស្លាប់នៃសត្វព្រៃ និងការសំយោគនៃអតិសុខុមប្រាណនៅក្នុងព្រៃនៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀងរបស់ស្ទឹងនេះ

៤.២.២ ទឹកក្រោមដី

ក្រុមការងារ SAWAC បានសិក្សា ទឹកក្រោមដីនៅតំបន់ខាងក្រោមទំនប់ Site A ដែលស្ថិតនៅក្នុងឃុំថ្មដូនពៅ ភូមិព្រៃកស្វាយ និងមានលទ្ធផលបញ្ជាក់ក្នុងតារាងខាងក្រោម ។

យោងតាមលទ្ធផលនៃការវាស់នីវ៉ូស្តាទិកបានបញ្ជាក់ថា ទឹកក្រោមដីនៅតំបន់គំរោងមាន ២ ស្រទាប់គឺ :

១- ស្រទាប់ទឹកក្រោមដីមិនខ្ចប់ (Unconfined Aquifer) ស្រទាប់នេះគឺមានជំរៅរាក់ បើប្រៀបធៀបទៅនឹងនីវ៉ូផ្ទៃដីខាងលើមានជំរៅចាប់ពី ០.៧ ម ទៅ ៥ ម ហើយមានទិសដៅហូរចុះទៅស្ទឹងជាយអារ៉ែង ។ ស្រទាប់នេះមានធារទឹកតិចប្រមាណ ពី ១២០ ទៅ ១000 ល/ម៉ ។ ចំពោះបរិមាណទឹកនៅរដូវប្រាំងមានការថយចុះ រហូតមានអណ្តូងខ្លះរីងគ្មានទឹកទៀតផង ។

២- ស្រទាប់ទឹកក្រោមដីខ្ចប់ (Confined Aquifer) ជាស្រទាប់ទឹកក្រោមដីដែលមានជំរៅចាប់ពី ១0 ម ទៅ ២0 ម ហើយមានសម្ពាធទឹកដែលមាននីវ៉ូស្តាទិកគិតពីផ្ទៃដីខាងលើប្រមាណ ៣ ម ទៅ ៦ ម ។ ស្រទាប់ទឹកក្រោមដីនេះមានបរិមាណធារទឹកប្រមាណ ពី ១ ទៅ ៧ ម^{3}/ម៉ ។

៣- ចំពោះលទ្ធផលពិនិត្យគុណភាពទឹកមានចែង ក្នុងចំណុច ៤.២.១.៧ ខាងលើ ។

Draft

តារាងលេខ១៩ : សិក្សានីវ៉ូស្តាទិកទឹកក្រោមដី

ល.រ	ប្រភេទអណ្តូង	ចំណុចយោងការ(ម)	ជំរៅអណ្តូង(ម)	ជំរៅទឹក(ម)	ទីវ៉ូស្តាទិក(ម)
១	អណ្តូងជីកនៅការិយាល័យ CI	X: 340260 Y: 1285296	៥	៤	១៧៦
២	អណ្តូងជីកស្ថិតនៅទល់មុខការិយាល័យ CI	X: 340143 Y: 1285275	២	០,៧	១៧៥
៣	អណ្តូងជីកស្ថិតនៅផ្ទះប្រជាជន	X: 340150 Y: 1285496	៣,៥	២,២	១៧៤
៤	អណ្តូងជីកស្ថិតនៅផ្ទះប្រជាជន	X: 340304 Y: 1285839	២,៥	១,៤២	១៧១
៥	អណ្តូងជីកស្ថិតនៅផ្ទះប្រជាជន	X: 340218 Y: 1285934	៤	៣	១៧៥
៦	អណ្តូងខួងស្ថិតនៅទីស្នាក់ការចិន	X: 340423 Y: 1285778	៣0	៥,៧៥	១៧១

សំគាល់ : - នីវ៉ូស្តាទិកធ្យៀបនីវ៉ូសមុទ្រ

- ជំរៅទឹក និងជំរៅអណ្តូង ធ្យៀបទៅនឹងផ្ទៃដីខាងលើ

៤.២.៣ ប្រព័ន្ធស្រោចស្រព (Irrigation System)

នៅក្នុងតំបន់ផ្ទៃអាងដែលនឹងត្រូវលិចនេះ យោងតាមការសិក្សារបស់ក្រុមការងារ SAWAC និង SBK មានដីស្រែចំការ (ដីកសិកម្ម) ប្រមាណ ២.៥៦៣ ហ.ត ហើយដីទាំងនោះពុំមានប្រព័ន្ធស្រោចស្រពទេ ។ សព្វថ្ងៃនេះប្រជាកសិករក្នុងតំបន់ពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង (របាយការណ៍ពីលោក **សាញ់ មន្ទីរត្ន** ប្រធានមន្ទីរធនធានទឹក និង ឧតុនិយម ខេត្តកោះកុង) ។

យោងតាមរបាយការណ៍របស់លោកប្រធានមន្ទីរ តំបន់គំរោងនេះពុំមានផែនការដើម្បីសាងសង់ប្រព័ន្ធស្រោចស្រពដល់ដីស្រែចំការរបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោងនោះទេ ដូច្នេះគ្មានប៉ះពាល់ដល់វិស័យប្រព័ន្ធស្រោចស្រពរបស់មន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក៏ដូចជាក្រសួងនោះទេ ។

៤.២.៤ លក្ខណៈសណ្ឋានភាពដី ប្រភេទដី និង ភូគព្ភសាស្ត្រ នៅក្នុងតំបន់គំរោង (Topography, Soil Type and Geology in Project Area)

៤.២.៤.១ សណ្ឋានភាពដី (Topography)

លក្ខណៈភូមិសាស្ត្ររបស់តំបន់គំរោង គឺស្ថិតនៅក្នុងតំបន់ជួរភ្នំក្រវ៉ាញ ដែលតំបន់អាងជាជ្រលងមានជួរភ្នំព័ទ្ធជុំវិញ ។ នៅក្នុងតំបន់អាងនេះមានរយៈកំពស់ចាប់ពី ១៨០ម ទៅដល់ ២១០ម ធ្យៀបនឹងនីវ៉ូសមុទ្រ (មើលផែនទីលេខ១ និងលេខ២) ។ ជំរាលដីជាមធ្យមក្នុងតំបន់គំរោងគឺ ប្រមាណ I=0.0063 ។

ចំពោះរយៈកំពស់ចាត់ស្ទឹងជាយអារ៉ែងមានកំពស់ពី ៨០ម-១០០ម ហើយចាត់ស្ទឹងនេះក្រាលទៅដោយសិលាប្រភេទថ្មខ្សាច់ និង ចាសាល ។ ផ្ទៃរាបស្មើនៃជ្រលងភ្នំបានកើតឡើងនៅយុគ្គទី ១ នៅច្រាំងទំនប់ផ្អែកខាងស្តាំ ដែលមានទទឹងប្រហែល ១គ.ម រីឯទទឹងច្រាំងទំនប់ខាងឆ្វេងមានត្រឹមតែ ២៥ម៉ែត្រ គឺវាបានបង្ហាញនូវលក្ខណៈមិនស្មើគ្នាទេ ។

៤.២.៤.២ ប្រភេទដី (Soil Type)

តាមផែនទីប្រភេទដីរបស់លោក Crocker ឆ្នាំ ១៩៦៣ មាត្រដ្ឋាន ១/១.000.000 បានបង្ហាញថា តំបន់ដីផ្ទៃអាងដែលនឹងត្រូវលិច ៩.៤៧៤ ហ.ត នេះមានសមាសភាពដី ៣ ប្រភេទគឺ ប្រភេទដី Acid Lithosols មានផ្ទៃដី ៥៥៩ ហិកតា .

Grey Hydromorphics ៨៨០៧ ហិកតា , Latosols ១០៨ ហិកតា ហើយនៅលើប្រភេទដីទាំងនេះ មានស្ពឹង និង ត្រពាំងធម្មជាតិ គឺ ១៥៦ ហិកតា ។

៤.២.៤.៣ ភូគព្ភសាស្ត្រ (Geology)

<u>លក្ខណៈស្រទាប់ថ្ម</u>

ភាគច្រើនទីតាំងទំនប់គឺមាន ដីល្បាប់ដែលកើតឡើងដោយសារលំហូរទឹកភ្លៀង (តាងដោយQ^{Pal}) ហើយកំណកដី (Q^{edl}) នៃស័ក្តិ៤ , សណ្ឋានដីកើតសម័យក្រោយស័ក្តិ ៣ (N_2) , និងសណ្ឋានដីកើតនៅពាក់កណ្តាលស័ក Jurassic (J_2) ចំពោះ សណ្ឋានថ្ម N_2 និង J_2 មាននៅបាតស្ពឹងហើយផ្ទាំងថ្មខ្លះទៀតមាននៅតាមច្រាំងសងខាងក្បែរជើងភ្នំ ។

➢ **ដីល្បាប់ដែលកើតឡើងដោយលំហូរនាំរបស់ទឹកភ្លៀង** Pluvial-Alluvial (Q^{Pal})

នៅស្រទាប់ដីខាងលើ គឺជាស្រទាប់ខ្សាច់ល្អិតៗ ដែលគ្មានពណ៌ស និងនៅជាប់ជាមួយចុណ្ណភាគតូចៗ ហើយនៅស្រទាប់ខាងក្រោម គឺជាដីឥដ្ឋល្បាយខ្សាច់ដែលមានលក្ខណៈមិនសូវស្អិតល្អ ហើយផ្នែកខ្លះទៀត គឺជាប្រភេទដីឥដ្ឋមានលាយសារធាតុសរីរាង្គ ជាទូទៅកំរាស់ដីស្រទាប់លើ គឺប្រហែល ២ម-៧.៥ម ហើយភាគច្រើនដីនេះលាតសន្ធឹងនៅតាមសងខាងច្រាំង និងនៅដាច់ចេញពីបាតស្ពឹង ។

➢ **កំណកកំទេចដី** Eluvium (Q^{edl})

ភាគច្រើន គឺជាដីឥដ្ឋ លាយដីល្បាប់ម៉ដ្ឋមានពណ៌ទឹកក្រូច, ពណ៌ក្រហមក្រម៉ៅ ជាប្រភេទដីស្អិតល្អ ហើយនៅផ្នែកខាងក្រោម មានកំទេចថ្មតូចៗ ធាតុផ្សំនៃកំទេចថ្មនោះគឺជា ថ្មភក់ និងថ្មបាសាល ។ ជាទូទៅកំរាស់ ស្រទាប់ដីនោះគឺមាន ០ម៉ែត្រទៅ ១៧.៥ ម៉ែត្រ ហើយភាគច្រើនគឺស្ថិតនៅតាមទីទួល និងតាមជើងភ្នំនៃច្រាំងស្ពឹងទាំងសងខាង ។

➢ **ថ្មកើតឡើងនៅស័ក្តិ៣ និងសម័យក្រោយនៃស័ក្តិ៣ (N_2)**

១- ថ្មបាសាលនៅយុគ្គទី២ (N_2^3)

ជាប្រភេទថ្មដែលមានពណ៌ប្រផេះ, ផ្នែកខ្លះទៀតគឺជាពណ៌ប្រផេះក្រម៉ៅនៅលាយឡំគ្នាមានមុខកាត់តូចៗ ហើយវិជ្ជមាត្រនៃមុខកាត់នេះ គឺ ២មម -២០មម ហើយទ្រង់ទ្រាយរបស់ថ្មនេះបើមើលទៅឃើញមានធាតុផ្សំផ្នែកខាងក្រោមនៃថ្មផ្ទាំងថ្ម មានលក្ខណៈជាកំទេចល្អិតៗ ។ ថ្មនេះមានកំរាស់ពី ០ម៉ែត្រទៅ ៣៥ម ហើយភាគច្រើនថ្មនេះស្ថិតនៅតាមបាតស្ពឹងក្បែរជំរាលជើងភ្នំនៃច្រាំងទាំងសងខាង ។

២- ថ្មភក់ល្បាយថ្មរ៉ែឥដ្ឋ (N_2^2)

ថ្មនេះមានពណ៌ច្រើនយ៉ាង គឺពណ៌ទឹកក្រូច និងពណ៌បៃតងលាយលឿង ។ ទំហំចុណ្ណភាគនៃសាច់ថ្មនេះគឺ ចាប់ពី ០.៥មម ទៅ ២០មម ។ វាកើតឡើងចន្លោះនៃស្រទាប់ថ្មបាសាល (ការបន្ទុះភ្នំភ្លើង) និងកំទេចកំណដីល្បាប់ ។

៣- ថ្មបាសាលនៅយុគ្គទី១ (N_2^1)

ថ្មនេះភាគច្រើនមានពណ៌ប្រផេះ និងពណ៌ត្សុងប្រផេះ មានសណ្ឋានសាច់ថ្មហាប់ល្អ ហើយផ្នែកខ្លះនៃថ្មមានទំរង់ជារន្ធតូចៗ ដែលមានវិជ្ជមាត្រប្រមាណ ០.៣ មម ទៅ ៣ មម ។ រាងសណ្ឋានថ្មនេះវាកើតឡើងតាមចន្លោះភ្ជុំដោយកំទេចថ្មតូចៗ ហើយមានកំរាស់ជាទូទៅគឺ ២ម ទៅ ២៤ម វាកប់នៅក្នុងជំរៅដីជ្រៅដោយមិនផុសចេញពីដីទេ ។

Draft

➢ ស្រទាប់ថ្មកើតនៅពាក់កណ្តាលសម័ក Jurassic (J_2):

១- ថ្មខ្សាច់ (J_2^4)

ថ្មនេះមានពណ៌លឿង និងទឹកក្រូច វាមានកំរាស់ស្តើង ទៅមធ្យម ស្ថិតនៅក្នុងជ្រលងជ្រៅ ហើយវាមានតែមួយស្រទាប់ កំរាស់ ០.១ម ទៅ ០.៣ម ។ ថ្មខ្សាច់នេះ ភាគច្រើនកើតឡើងពីខ្សាច់ម៉ដ្ត ហើយនៅផ្នែកខាងក្រោមនៃផ្ទាំងថ្មនេះកើតឡើងពីខ្សាច់ល្អិត ។ កំរាស់នៃស្រទាប់ថ្មនេះជាទូទៅ មានកំរាស់ពី ០ម ទៅ ១៦ម ភាគច្រើនស្ថិតនៅផ្នែកខាងលើនៃភ្នំ ដែលមាននៅច្រាំងទាំងសងខាងនៃស្ទឹងជាយអារ៉ែង ។

២- ថ្មភក់ឈ្យាប់ម៉ដ្ត (J_2^3)

ថ្មនេះមានពណ៌ក្រហមក្រម៉ៅ និងពណ៌ប្រផេះចាស់, វាមានស្រទាប់ពីស្តើងទៅមធ្យម ។ ថ្មនេះមានស្រទាប់ស្ទើសាច់ កំរាស់ពី ០.០៥ម ទៅ ០.៤ម ។ ជាទូទៅស្រទាប់ថ្មនេះមានចាប់ពី ០ម ទៅ ១៥ម ហើយភាគច្រើនថ្មនេះលាតសន្ធឹងពីជំរាលភ្នំផ្នែក ខាងឆ្វេងនៃច្រាំងស្ទឹង ។

៣- ថ្មខ្សាច់ជាមួយថ្មភក់ (J_2^2)

ថ្មនេះភាគច្រើនមានពណ៌លឿង និងពណ៌ទឹកក្រូច វាមានកំរាស់មធ្យម ទៅក្រាស់នៅបាត ដែលមានស្រទាប់ស្ទើសាច់ពី ០.៣ម ទៅ ២ម ភាគច្រើននៃស្រទាប់ថ្មភក់ មានពណ៌ប្រផេះក្លឹផ្ទៃកៗ ដែលមានកំរាស់ពី ០.០៥ម ទៅ ០.៣ម។ ភាគច្រើននៃថ្មនេះ គឺថ្មខ្សាច់ ដែលកើតឡើងពីខ្សាច់ម៉ដ្ត និងផ្សារភ្ជាប់គ្នាជាមួយដុំថ្មល្អិតៗ ។ ភាគរយនៃថ្មភក់នេះគឺ មានចាប់ពី ០% ទៅ ១៣% ហើយកំរាស់ថ្មនេះជាទូទៅចាប់ពី ០ម ទៅ ៤០ម ។ ភាគច្រើនមាននៅជំរាលច្រាំងផ្នែកខាងឆ្វេង ។

៤- ថ្មភក់ឈ្យាប់ និងថ្មភក់ (J_2^1)

ថ្មនេះមានពណ៌ក្រម៉ៅ កំរាស់បាតថ្មមានកំរាស់ពីមធ្យមរហូតដល់កំរាស់ក្រាស់ ។ ស្រទាប់កំរាស់ គឺចាប់ពី ០.២ម ទៅ ០.៧ម, ថ្មភក់នេះភាគច្រើនជាប្រភេទថ្មភក់លាយគ្រាប់ខ្សាច់ល្អិតៗ និងថ្ម granat តូចៗ ។ កំរាស់ថ្មភក់នេះគឺ ០% ទៅ ២៥% ។ ស្រទាប់កំរាស់ថ្មនេះជាង ៤០ម ហើយភាគច្រើនលាតសន្ធឹងតាមច្រាំងស្ទឹងនៅខាងស្តាំដៃ ។

ប្រភេទសិលានៅបាតស្ទឹងជាយអារ៉ែងជាប់នឹងទីតាំងទំនប់ Site A នៃតំបន់គំរោងវារីអគ្គិសនីជាយអារ៉ែង ។



ប្រភេទសិលានៅបាតស្ទឹងជាយអារ៉ែងទីតាំង ទំនប់ Site A នៃតំបន់គំរោងវារីអគ្គិសនីជាយអារ៉ែងដែលខួងសិក្សាគ្រិះដោយក្រុមហ៊ុនចិន ជំរៅខួងដល់ ៨០ ម) ។

៤.២.៥ ព្រៃឈើ (Forestry)

ក្រុមការងារបានចែកតំបន់គំរោងជាពីរផ្នែកគឺតំបន់អាង និងតំបន់ខាងក្រោមអាង។ យោងតាមតាមផែនទីប្រភេទព្រៃឈើ របស់ JICA ឆ្នាំ ២០០២ មាត្រដ្ឋាន ១/១.000.000 តាមរូបភាពថតពីលើអាកាសដែលមាន Resolution 1m year 2005 និង យោងការចុះធ្វើការសិក្សាផ្ទាល់របស់ក្រុមការងារ SAWAC បានបង្ហាញថា តំបន់គំរោងនេះមានប្រភេទព្រៃឈើ ដូចតទៅ:

៤.២.៥.១ តំបន់អាងដែលនឹងត្រូវលិច ខាងលើទំនប់ Site A

- ព្រៃស្រោង ៨៧៤ ហិកតា
- ព្រៃអ្នកតា (ព្រៃស្រោង) ៦៦ ហិកតា
- ព្រៃពាក់កណ្តាលស្រោង ៣៧៩០ ហិកតា
- ព្រៃល្បោះ ៣៧ ហិកតា
- ព្រៃដុះឡើងវិញ ៧២៨ ហិកតា
- ផ្ទៃទឹក ១៥៦ ហិកតា

<u>សំគាល់:</u> - ផ្ទៃដីដែលត្រូវលិចប្រមាណ ៩.៤៧៤ ហ.ត (គិតត្រឹមនីវ៉ូ ២០៥ ម)។

- ព្រៃឈើដែលដុះឡើងវិញគឺ ព្រៃដែលដុះនៅលើដីកសិកម្មចាស់ជំនាន់ប៉ុលពត ។

យោងតាមក្រុមការងាររបស់ SAWAC Consultants for Development បានធ្វើការសិក្សារាប់ព្រៃឈើ ៤ ប្រភេទ នៅក្នុងអាងដែលនឹងត្រូវលិចនេះ គឺព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ និងព្រៃដុះឡើងវិញ ។ ទំហំដីព្រៃដែលរាប់ មួយគំរូសាកៗគឺ ២0 x ៣0 = ៦00ម^{២} ចំពោះព្រៃស្រោងមាន ៣ គំរូសាក សរុបផ្ទៃព្រៃដែលសិក្សា ១៨00 ម^{២} , ព្រៃពាក់កណ្តាលស្រោងមាន ៣ គំរូសាក សរុបផ្ទៃព្រៃដែលសិក្សា ១៨00 ម^{២} , ព្រៃល្បោះមាន ៣ គំរូសាក សរុបផ្ទៃព្រៃដែលសិក្សា ១៨00 ម^{២} , និងព្រៃដុះឡើងវិញមាន ៣ គំរូសាក សរុបផ្ទៃព្រៃដែលសិក្សា ១៨00 ម^{២} ហើយទីតាំងសិក្សាព្រៃឈើ មានបង្ហាញ ក្នុងផែនទីលេខ ២ និង ៣ ។

(<u>បញ្ជាក់</u> : អ្នកចង្អុលបង្ហាញឈ្មោះព្រៃឈើ គឺជាអ្នកដែលមានដើមកំណើតនៅក្នុងតំបន់គំរោងនេះ ហើយជាអ្នកចេញចូលទំបន់នេះដើម្បីប្រមូលអនុផលព្រៃឈើ ដែលមានឈ្មោះ **ហាស់ ម៉ន** ជាមេភូមិជំនាប់ អាយុ ៤៩ ឆ្នាំ , លោក **ម៉ម ផ្ដេន** ជាប្រជាជន អាយុ ៦២ ឆ្នាំ , និងលោក **ឆាន់ សារ៉ូន** ជាប្រជាជន អាយុ ៥៥ ឆ្នាំ ។

ការសិក្សារាប់ព្រៃឈើលើផ្ទៃដីសរុបនៅក្នុងអាងដែលត្រូវលិចមាន ៧២00ម^{២} ខាងលើអាចធ្វើការសន្និដ្ឋានដូចតទៅ :

- <u>ព្រៃស្រោង</u> :

យោងតាមការសិក្សារាប់ព្រៃឈើលើផ្ទៃដី ១៨00ម^{២} នៃព្រៃស្រោង ដែលមានផ្ទៃដី ៨៧៤ ហិកតា ក្នុងផ្ទៃអាងដែលត្រូវលិចនេះ មានដើមឈើ ៥៩ប្រភេទ (មើលតារាងលេខ ១0 ខាងក្រោម)។

ឧបសម្ព័ន្ធ១១០ : ការសិក្សាអំពីព្រៃស្រោងនៅក្នុងផ្ទៃរាងដែលត្រូវលិចលើទំហំផ្ទៃដីក្នុងមួយកន្លែង ៦០០ម២ (សិក្សា៣គំរូសាក)

ថ្ងៃទី ០៥/១១ ដល់ ៣១/១២/២០០៧ (ចំនួនយសិក្សាមាននៅក្នុងខ្ទមសម្ព័ន្ធ ៣)

ល.រ	ឈ្មោះឈើ	មុខកាត់ឈើគិតជា មិលីម៉ែត្រ សិក្សាលើផ្ទៃដី ៣ x ៦០០ម២ = ១៨០០ម២ (៣គំរូសាក , ១គំរូសាក = ៦០០ម២)																															
		≤ ១០០ មម				២០០ មម				៣០០ មម				៤០០ មម				៥០០ មម				៦០០ មម				៧០០ មម				១០០០ មម			
		001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប
១	ត្រសេក				-				-	1			1	2			2	1			1				-	1			1				-
២	ក្តង	20		4	24				-				-				-				-				-				-				-
៣	បន្ទាត់	1	1	15	17			1	1				-				-				-				-				-				-
៤	ល្វៀង	1			1				-	2			2	1			1				-				-				-				-
៥	ក្រចកអណ្តើក	1	2		3		2		2		1		1				-				-				-				-				-
៦	កំញ្ជាន	6			6				-				-				-				-				-				-				-
៧	ង្គ	12	1	3	16	2	1	1	4				-				-				-				-				-				-
៨	ឈើស្រួយ	3			3				-				-				-				-				-				-				-
៩	ឈើស្ពយ	5			5				-				-				-				-				-				-				-
១០	ដូក				-	1			1				-				-				-				-				-				-
១១	ត្នោតមាស់		1		1			5	5	2	1	1	4	1			1	1			1				-	1			1				-
១២	សង្ហារ	8	14	6	28		1		1				-				-				-				-				-				-
១៣	ក្ងាស	1			1				-				-				-				-				-				-				-
១៤	ពោធិ៍ចង្អារ	8			8				-				-				-				-				-				-				-
១៥	ខ្នុរព្រៃ	4			4				-				-				-				-				-				-				-
១៦	ក្រាយស	7			7	2			2				-				-				-				-				-				-
១៧	ឈ្មេចអាល				-		1		1	1			1				-				-				-				-				-
១៨	ជើងចាប	6	1	2	9				-				-				-				-				-				-				-
១៩	ក្ងាវប្រើស	2			2	1			1	4			4				-				-				-				-				-
២០	ត្រាំង	5	1	1	7			4	4				-				-				-				-				-				-

ល.រ	ឈ្មោះឈើ	មុខកាត់ឈើគិតជា មិលីម៉ែត្រ សម្រាប់លើផ្ទៃដី ៣ x ៦០០ម² = ១៨០០ម² (៣គុំ១ , ១គុំ១ = ៦០០ម²)																															
		≤ ១០០ មម			សរុប	២០០ មម			សរុប	៣០០ មម			សរុប	៤០០ មម			សរុប	៥០០ មម			សរុប	៦០០ មម			សរុប	៧០០ មម			សរុប	១០០០ មម			សរុប
		001	002	003		001	002	003		001	002	003		001	002	003		001	002	003		001	002	003		001	002	003		001	002	003	
២១	ណេះកេន		1		1			1	1		1	1	2	1	1		2				-				-				-				-
២២	ទាបព្រៃ	1			1				-				-				-				-				-				-				-
២៣	ខ្ទះ	1			1				-	2			2				-				-				-				-				-
២៤	ស្រះខ្ទៅ	5			5	1			1				-				-				-				-				-				-
២៥	ផ្សេ	1	1		2		1	2	3				-				-				-				-				-				-
២៦	ក្ម	1			1				-				-				-				-				-				-				-
២៧	ពញា				-	1			1				-				-				-				-				-				-
២៨	ពង្រ				-				-	1			1				-				-				-				-				-
២៩	កំបុត				-				-	1			1				-				-				-				-				-
៣០	អង្គត់ខ្ទៅ	3			3				-				-				-				-				-				-				-
៣១	ភ្ជកំប្លេក	1			1	1			1				-				-				-				-				-				-
៣២	ចំបក់	1			1				-				-				-				-				-				-				-
៣៣	ត្រាល		1	5	6				-				-				-				-				-				-				-
៣៤	ឈើពួរ		8		8		4		4		5		5		9		9		1		1				-				-				-
៣៥	ឈើទាលទឹក				-				-		1		1		1		1				-				-				-				-
៣៦	ញារ		3	1	4				-				-				-				-				-				-				-
៣៧	អន្ទែងភ្លុំ		1		1				-				-				-				-				-				-				-
៣៨	ត្រមូច		3		3		1		1				-				-				-				-				-				-
៣៩	ស្វាក្របី		3	4	7		2		2				-				-				-				-				-				-
៤០	លលក				-				-		1		1				-				-				-				-				-
៤១	ត្រាប់ខ្ទៅ	1			1				-				-				-				-				-				-				-
៤២	ដកការ			1	1				-				-				-				-				-				-				-
៤៣	ស្រោមជាវ			1	1				-				-				-				-				-				-				-

ល.រ	ឈ្មោះឈើ	មុខកាត់ឈើគិតជា មីលីម៉ែត្រ សិក្សាលើផ្ទៃដី ៣ x ៦០០ម² = ១៨០០ម² (៣គំរូសាក , ១គំរូសាក = ៦០០ម²)																																	
		≤ ១០០ មម				២០០ មម				៣០០ មម				៤០០ មម				៥០០ មម				៦០០ មម				៧០០ មម				១០០០ មម			
		001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប
៤៤	ក្ងាស				-				-			1	1				-				-				-				-				-
៤៥	សណ្ណែកព្រៃ			4	4				-				-				-				-				-				-				-
៤៦	អំបែងថ្ម			2	2				-				-				-				-				-				-				-
៤៧	ដំរចុង (ខ្ទុ)				-				-			1	1				-				-				-				-				-
៤៨	បត្រីក្ស				-			1	1			1	1				-				-				-				-				-
៤៩	ខ្ចាំ				-				-			1	1				-				-				-				-				-
៥០	ផ្ទេញត្រី				-				-			2	2				-				-				-				-				-
៥១	ដងចៃ			2	2			2	2				-				-				-				-				-				-
៥២	ជាយពុកាំង			2	2				-				-				-				-				-				-				-
៥៣	ឥតីរ				-				-				-				-				-				-			1	1				-
៥៤	បង្ហូ			1	1				-				-				-				-				-				-				-
៥៥	ត្រកែកព្រៃ				-			1	1				-				-				-				-				-				-
៥៦	ឈើម៉ាស់				-				-			1	1				-				-				-				-				-
៥៧	ឈើទាល				-				-				-				-				-				-				-			1	1
៥៨	ឈើស		1		1		1	1	2				-				-				-				-				-				-
៥៩	ត្រសង		1		1				-				-				-				-				-				-				-

ក្រុជាតិស្រមាប់ក្រោម : បត្រីក្ស, ល្ហាក់, កូនសង្ហារ, កូនផ្ដៅ, វល្ល៍រមៀត, វល្ល៍ទីក, វល្ល៍កណ្ដាប់ចង្ហេរ, ម្ទេសព្រៃ, កូនញ្ជរ, វល្ល៍ទ្រាល, វល្ល៍ធ្នក, ក្ដាតព្រៃ, សាគូព្រៃ, វល្ល៍ត្រី, កូនឈើស, កូនស្ទាក្របី, កូនភ្លង, ប្រឡាយយុទ្ធការ, សេមាន់, កូនផ្ទុង, វល្ល៍ខ្ចូ, ស្ងៅតាសិត, កូនជើងចាប, កូនក្ងៀ

យោងតាមតារាងលេខ ១០ ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៣០០មម ឡើងទៅគឺ :

<u>តារាងលេខ១០ (ក)</u> : ចំណាត់ថ្នាក់ឈើនៅក្នុងព្រៃស្រោងក្នុងផ្ទៃអាងដែលត្រូវលិច ដែលមានអង្កត់ផ្ចិតចាប់ពី ៣០០មម ឡើងទៅ

No.	LOCNAM	FANAM	SPENAM	QUACLA	Diameter (mm)					
					300	400	500	600	700	1000
១	ត្រសេក	CEASALPINIACEAE	*Peltophorum Ferrugineum*	No. 1	1	2	1		1	
២	ឈើទាលទឹក	DIPTERACARPACEAE	*Dipterocarpus Alatus*	No. 2	1	1				
៣	ជ័រចុង (ខ្ជូវ)	DIPTERACARPACEAE	*Shorea Vulgaris*	No. 2	1					
៤	ច្រម៉ាស់	DIPTERACARPACEAE	*Vatica Astrotricha /*	No. 2	1					
៥	ឈើទាល	DIPTERACARPACEAE	*Dipterocarpus Alatus*	No. 2						1
៦	ល្ងៀង	HYPERICACEAE	*Cartoxylon Orunifolium*	No. 3	2	1				
៧	ព្ធូស	GUTTIFERES	*Garcinia Ferra*	No. 3	1					
៨	គុម្ពរមាស់	THEACEAE	*Schima Sp*	Other	4	1	1		1	
៩	ពញ្ជាប្រើស	STERCULIACEAE	*Pterospermum Diversifolium*	Other	4					
១០	សេមាន់	POACEAE	*Nephelium Xerospermum*	Other	2	2				
១១	ខុះ		*Fagaceae*	Other	2					
១២	ពង្រ	SAPINDACEAE	*Schleicher Oleosa*	Other	1					
១៣	បព្រីក្ស	CEASALPINIACEAE	*Cassia Javanica*	Other	1					
១៤	ធ្មេញត្រី	EUPHORBIAECAE	*Bridelia Cambodiana*	Other	2					
១៥	ក្រចកអណ្តើក			UNKN	1					
១៦	កន្ទេចអាល			UNKN	1					
១៧	កំបុត			UNKN	1					
១៨	ឈើពួរ			UNKN	5	9	1			
១៩	ឡលក			UNKN	1					
២០	ខាំភ្ជួ			UNKN	1					

- **<u>ព្រៃពាក់កណ្តាលស្រោង</u> :**

យោងតាមការសិក្សារាប់ព្រៃឈើលើផ្ទៃដី ១៨០០ម^{២} នៃព្រៃពាក់កណ្តាលស្រោង ដែលមានផ្ទៃដី ៣៧៩០ ហិកតា ក្នុងផ្ទៃអាងដែលត្រូវលិចនេះ មានដើមឈើ ៤៣ប្រភេទ (មើលតារាងលេខ ១១ ខាងក្រោម) ។

Draft

តារាងលេខ១១ : ការសិក្សាអំពីព្រៃឈើកាត់កណ្តាលស្រោចនៅក្នុងផ្ទៃអាងដែលត្រូវលិច លើទំហំផ្ទៃដីក្នុងមួយកន្លែង ៦០០ម២

(សិក្សា៣គំរូសាក) ថ្ងៃទី ០៥/១១ ដល់ ៣១/១២/២០០៧ (ចំនួនសិក្សាមាននៅក្នុងឧបសម្ព័ន្ធ ៣)

ល.រ	ឈ្មោះឈើ	បុខភាគ់ឈើគិតជា មីលីម៉ែត្រ សិក្សាលើផ្ទៃដី ៣ x ៦០០ម២ = ១៨០០ម២ (៣គំរូសាក , ១គំរូសាក = ៦០០ម២)																															
		≤ ១០០ មម			សរុប	២០០ មម			សរុប	៣០០ មម			សរុប	៤០០ មម			សរុប	៥០០ មម			សរុប	៦០០ មម			សរុប	៧០០ មម			សរុប	៨០០ មម			សរុប
		001	002	003		001	002	003		001	002	003		001	002	003		001	002	003		001	002	003		001	002	003		001	002	003	
១	ក្រចកអណ្តើក	11			11	6	1	1	8	1	1		2				-				-				-				-				-
២	ក្ងង	6	1	43	50	1		7	8				-				-				-		1		1				-				-
៣	ត្រកៀកព្រៃ	2	6		8	1			1	1	1		2		1		1				-				-				-				-
៤	ឈើចាល	2	1		3	7	2		9	11	3		14	3	1		4	2	1		3				-				-				-
៥	ត្រាក់ស	5			5	3			3				-				-				-				-				-				-
៦	ជីវ៉ែក	1			1				-				-				-				-				-				-				-
៧	ពញ្ញា	3			3	1	3		4		1		1				-				-				-				-				-
៨	អំបែងថ្ម	1			1	1			1	1			1				-				-				-				-				-
៩	ពពួល	1			1				-	1			1				-				-				-				-				-
១០	ក្រចកចាប	1			1				-				-				-				-				-				-				-
១១	ឥតីរ				-	1			1		5		5				-				-				-		1		1		1		1
១២	កំបុត	1			1				-				-				-				-				-				-				-
១៣	ដ្ឋាង				-	1			1				-				-				-				-				-				-
១៤	ដើងចាប	2			2				-				-				-				-				-				-				-
១៥	ក្ងងកែវ	1			1				-				-				-				-				-				-				-
១៦	ឈើត្រាវ៉ាម	1			1				-				-				-				-				-				-				-
១៧	សង្ហារ	1			1				-				-				-				-				-				-				-
១៨	ច្រកាង		1		1		2		2				-				-				-				-				-				-
១៩	ឈើកូរ				-		1		1				-		1		1				-		1		1				-				-
២០	ក់ង				-				-				-				-				-		1		1				-				-

ល.រ	ឈ្មោះឈើ	២០០ មម				២០០ មម				៣០០ មម				៤០០ មម				៥០០ មម				៦០០ មម				៧០០ មម				៨០០ មម			
		≤ ១០០ មម																															
		001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប	001	002	003	សរុប
		២ម៉ឺ២																															
២១	ក្រមែងទឹក		1		1			1	1			1	1				-				-				-				-				-
២២	ពាយពុកាង		3		3		3		3		3		3				-				-				-				-				-
២៣	ត្រាង			1	1			1	1			1	1			1	1			1	1		1		1				-				-
២៤	ក្រវ		1		1		2		2				-				-				-				-				-				-
២៥	ទ្ធក				-		1		1			1	1			1	1				-				-				-				-
២៦	អង្គញ្ញស្ថា				-		1		1				-				-				-				-				-				-
២៧	ឈើស្នួយ		1		1				-				-				-				-				-				-				-
២៨	ចំបក់				-				-			1	1				-				-				-				-				-
២៩	ត្រាត់ស				-				-			1	1				-				-				-				-				-
៣០	ផ្ទៅក			2	2				-			2	2				-				-				-				-				-
៣១	ស្នាច់ដុំ				-			2	2				-				-				-				-				-				-
៣២	អង្គត់ខ្ចៅ			6	6			1	1				-				-				-				-				-				-
៣៣	ការ៉ូចអាល			1	1				-				-				-				-				-				-				-
៣៤	ឈើស			1	1				-				-				-				-				-				-				-
៣៥	ច្រម៉ាស់			1	1			2	2			1	1				-				-				-				-				-
៣៦	ម៉ាក់ព្រាង			1	1				-				-				-				-				-				-				-
៣៧	ផ្ទង				-			1	1			2	2				-				-				-				-				-
៣៨	បន្ទាត់			1	1				-				-				-				-				-				-				-
៣៩	ត្រមូរមាស់				-				-			1	1				-				-				-				-				-
៤០	ក្រយោង				-				-				-			1	1				-				-				-				-

ល.រ	ឈ្មោះឈើ	មុខកាត់ឈើគិតជា មិលីម៉ែត្រ សំភ្យារលើផ្ទៃដី ៣ x ៦០០ម² = ១៨០០ម² (៣គ្រាប់សោត , ១គ្រាប់សោត = ៦០០ម²)																															
		≤ ១០០ មម			សរុប	២០០ មម			សរុប	៣០០ មម			សរុប	៤០០ មម			សរុប	៥០០ មម			សរុប	៦០០ មម			សរុប	៧០០ មម			សរុប	៨០០ មម			សរុប
		001	002	003		001	002	003		001	002	003		001	002	003		001	002	003		001	002	003		001	002	003		001	002	003	
៤១	ពពេល				-				-			1	1				-				-				-				-				-
៤២	ពពូល				-			1	1				-				-				-				-				-				-
៤៣	ច្រខ្ជង				-				-				-				-			1	1				-				-				-
ក្រៅជាកិស្សទាប់ក្រោម : កូនផ្ដៅ, ផ្ដៅអាចម៍មាន់, កូនត្រាក់ស, ទាងខ្មៅ, វល្លិ៍ឥង្គត់, វល្លិ៍ទឹក, វល្លិ៍ទន្ទេញ, វល្លិ៍ទ្រាល, វល្លិ៍ធ្លក, សាគូព្រៃ, វល្លិ៍ត្រី, វល្លិ៍តាព្រហ្ម, វល្លិ៍ចំពាក់ស, វល្លិ៍ក្រញូង, វល្លិ៍ក្រពើភ្លើ, វល្លិ៍ដោះគន់, វល្លិ៍គុយ, កូនអង្គត់ខ្មៅ, កូនទាងដាវ, កូនទ្រាល, ប្រឡាយយុទ្ធកា																																	

Draft

យោងតាមតារាងលេខ ១១ ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៣០០មម ឡើងទៅគឺ :

<u>តារាងលេខ១១ (ក)</u> : ចំណាត់ថ្នាក់ឈើនៅក្នុងព្រៃពាក់កណ្តាលស្រោងក្នុងផ្ទៃអាងដែលត្រូវលិច ដែលមានអង្កត់ផ្ចិតចាប់ពី ៣០០មម ឡើងទៅ

No.	LOCNAM	FANAM	SPENAM	QUACLA	Diameter (mm)					
					300	400	500	600	700	900
១	ពពួល	VERBENACEAE	*Vitex Sp*	LUXURY	1					
២	រ៉ាំង	DIPTERACARPACEAE	*Pentacme Siamenesis*	No. 1				1		
៣	ពពេល	DIPTERACARPACEAE	*Hopea Recopei / Shoprea*	No. 1	1					
៤	ឈើទាល	DIPTERACARPACEAE	*Dipterocarpus Alatus*	No. 2	14	4	3			
៥	គគីរ	DIPTERACARPACEAE	*Shore Pierrei*	No. 2	5				1	1
៦	ផ្ទៀក	DIPTERACARPACEAE	*Anishoptera Grabra*	No. 2	2					
៧	ច្រម៉ាស់	DIPTERACARPACEAE	*Vatica Astrotricha*	No. 2	1					
៨	ត្រមែងទឹក	RHIZOPHORACEAE	*Carallia Lucida*	No. 3	1					
៩	បាយពូរ៉ាំង			No. 3	3					
១០	ព្រីង	MYRTACEAE	*Eugenia Spp*	No. 3	1	1	1	1		
១១	ធ្លក	ROSACEAE	*Parinarium Anamensis*	No. 3	1	1				
